# ជំពូកទី ២: ស្ថាប័ន និង ក្របខ័ណ្ឌច្បាប់

## ២.១ ស្ថាប័នសំខាន់ៗ

គំរោងវារីអគ្គិសនីស្នើសុំ គឺមានការត្រួតពិនិត្យលើលក្ខណៈបច្ចេកទេសដោយផ្ទាល់ពីអាជ្ញាធរអគ្គិសនីកម្ពុជា (EAC) និងក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល (MIME)។ យោងលើទីតាំងគំរោងស្ថិតនៅក្នុងខេត្តកោះកុង នោះការគ្រប់គ្រង ធនធានសង្គមនិងការការពារធនធានធម្មជាតិជុំ រួមមានស្ថាប័នទទួលខុសត្រូវសំខាន់ៗដូចតទៅ: អាជ្ញាធរខេត្តកោះកុង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ (MAFF) . WildAid/Wildlife Alliance. អង្គការអភិរក្សអន្តរជាតិ (CI) និងក្រសួងបរិស្ថាន (MoE)។ ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅ ឬការតាំងលំនៅដ្ឋានឡើងវិញរបស់ជនឬសហគមន៍ដែលរងផលប៉ះពាល់ និងការរៀបចំផ្ទៃដីសំរាប់គំរោង នោះស្ថាប័នទទួលខុសត្រូវគឺ គណៈកម្មាការអន្តរក្រសួងរៀបចំការតាំងទីលំនៅសារជាថ្មី (IRC) ដែលដឹកនាំដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (MEF) ដែលក្នុងនោះមានក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ (MLMUPC) ជាសមាជិកសំខាន់ផងដែរ។ ពាក់ព័ន្ធជាមួយនឹងធនធានទឹក ក្រសួងធនធានទឹក និង ឧតុនិយម (MoWRAM) គឺជាស្ថាប័នសំខាន់ទទួលបន្ទុកការងារធនធានទឹក។ ដោយគំរោងមានការវិនិយោគទ្រង់ទ្រាយធំ នោះក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (MEF) ព្រមទាំងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ជាស្ថាប័នចំបង ក្នុងការសំរេចលើការងារវិនិយោគទុន។

Draft

## ២.២ ច្បាប់និងគោលការណ៍ណែនាំដែលទាក់ទងនឹងគំរោង

ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និង គោលការណែនាំ សំខាន់ៗមួយចំនួន យកមកប្រើប្រាស់សំរាប់ការសិក្សារៀបចំគំរោងវារីអគ្គិសនីស្ទឹងតាតៃ មានដូចតទៅ ÷

### *ក) រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣*

ក្នុងផ្នែកសេដ្ឋកិច្ចនៅក្នុងជំពូកទី ៥ នៃរដ្ឋធម្មនុញ្ញបានចែងថា:

**មាត្រា ៥៨:** ទ្រព្យសម្បត្តិរបស់រដ្ឋមានជាអាទិ៍ ដីធ្លី ក្រោមដី ភ្នំ សមុទ្រ បាតសមុទ្រ ក្រោមបាតសមុទ្រ ឆ្នេរសមុទ្រ អាកាស កោះ ទន្លេ ព្រែក ស្ទឹង បឹង ព្រៃឈើ ធនធានធម្មជាតិ មជ្ឈមណ្ឌលសេដ្ឋកិច្ចវប្បធម៌ មូលដ្ឋានការពារប្រទេស សំណង់ផ្សេងៗទៀត ដែលបានកំណត់ថាជារបស់រដ្ឋ។

ការគ្រប់គ្រង ការប្រើប្រាស់និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ នឹងត្រូវកំណត់ក្នុងច្បាប់។

**មាត្រា ៥៩:** រដ្ឋត្រូវរក្សាការពារបរិស្ថាន និងតុល្យាភាពនៃភោគទ្រព្យធម្មជាតិ ហើយត្រូវចាត់ចែងឱ្យមានផែនការច្បាស់លាស់ ក្នុងការគ្រប់គ្រងមានជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ ភូគព្ភសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាត និងឧស្ម័ន ថ្ម និងខ្សាច់ ត្បូងថ្ម ព្រៃឈើ និងអនុផលព្រៃឈើ ពពួកសត្វព្រៃ បច្ចាជាតិ និង ធនធានជលផល ។

**មាត្រា ៦១:** រដ្ឋាភិបាលជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅគ្រប់វិស័យទាំងអស់ និង នៅតាមតំបន់ជនបទ ជាពិសេស កសិកម្ម សិប្បកម្ម ឧស្សាហកម្ម ដោយមានការយកចិត្តទុកដាក់ទៅលើនយោបាយទឹក អគ្គិសនី ផ្លូវថ្នល់ មធ្យោបាយដឹកជញ្ជូនផ្សេងៗ បច្ចេកវិទ្យាទំនើប និង ប្រព័ន្ធឥណទាន ។

## ខ) ព្រះរាជក្រឹត្យស្តីពីការគ្រប់គ្រងតំបន់ការពារធម្មជាតិ

ព្រះរាជក្រឹត្យស្តីពីការគ្រប់គ្រងតំបន់ការពារធម្មជាតិត្រូវបានអនុម័តដោយរដ្ឋសភាជាតិ ចុះថ្ងៃទី ២៩ ខែតុលា ឆ្នាំ ១៩៩៣ ហើយក្រឹត្យនេះ មានអនុភាពជាគតិយុត្តិទូទាំងព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃឡាយព្រះហស្តលេខា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ។ ច្បាប់នេះមានគោលដៅដូចតទៅ ÷

**មាត្រា ១:** ការទទួលខុសត្រូវលើតំបន់ការពារធម្មជាតិ

រដ្ឋលេខាធិការដ្ឋានគ្រប់គ្រងបរិស្ថាន ទទួលខុសត្រូវក្នុងការដឹកនាំគ្រប់គ្រងធ្វើផែនការ និងអភិវឌ្ឍន៍ប្រព័ន្ធតំបន់ការពារធម្មជាតិរបស់ជាតិ រួមមានការការពារបរិស្ថាន ដី ព្រៃឈើ តំបន់ដីសើម និង តំបន់ឆ្នេរ ។ រដ្ឋលេខាធិការដ្ឋានគ្រប់គ្រងបរិស្ថានមានសិទ្ធិអំណាចបង្កើត និងធ្វើជាប្រធានគណៈកម្មាធិការសមស្រប សំរាប់សំរបសំរួលអន្តរក្រសួងលើបន្ទាត់នយោបាយ និងបច្ចេកទេស។ ការគ្រប់គ្រង និងអភិបាល ប្រព័ន្ធតំបន់ការពារធម្មជាតិរបស់ជាតិ ជាការទទួលខុសត្រូវរួមរបស់រដ្ឋលេខាធិការដ្ឋានគ្រប់គ្រងបរិស្ថាន ដោយសហការជាមួយស្ថាប័នមានសមត្ថកិច្ចឯទៀត ។

ប្រព័ន្ធនេះរួមបញ្ចូលរាល់ប្រភេទដែនបំរុងទុកសំរាប់ទិសដៅគ្រប់គ្រងដូចតទៅ:

១- **ឧទ្យានធម្មជាតិ :** ដែនធម្មជាតិ និងទស្សនីយភាពដែលត្រូវការពារ ដើម្បីបំរើអោយ វិទ្យាសាស្ត្រ ការអប់រំ និង ការកំសាន្ត ។

២- **ដែនជំរកសត្វព្រៃ:** ដែនធម្មជាតិដែលធានានូវលក្ខខ័ណ្ឌធម្មជាតិ ចាំបាច់ក្នុងការការពារ ប្រភេទ សត្វព្រៃ និងរុក្ខជាតិរបស់ជាតិសំខាន់ៗ និង សហគមន៍ធម្មជាតិ ឬ លក្ខណៈរូបសាស្ត្ររបស់ បរិស្ថានជាទីដែលភាវៈទាំងនេះត្រូវការជាពិសេសនូវអន្តរាគមន៍ពីមនុស្សសំរាប់ភាពស្ថិតស្ថេរ របស់វា ។

៣- **តំបន់ការពារទេសភាព:** តំបន់ដែលត្រូវថែទាំទេសភាពធម្មជាតិ និង ពាក់កណ្តាលធម្មជាតិសំខាន់ៗសំរាប់រមណីយដ្ឋានដល់សាធារណៈជនក្នុងការសំរាកកំសាន្ត និង ធ្វើទេសចរណ៍ ។

៤- **តំបន់ដែលទទួលរងនូវការប្រើប្រាស់ច្រើនមុខ:** តំបន់ដែលផ្តល់នូវភាពស្ថិតស្ថេរលើប្រភពទឹក ព្រៃឈើ សត្វព្រៃ ត្រី វាលស្មៅ និង ការកំសាន្តដែលតំរូវអោយមានការអភិវឌ្ឍន៍អភិរក្ស ធម្មជាតិក្នុងគោលដៅចំបងនៃសកម្មភាពសេដ្ឋកិច្ច ។



Draft

**<u>មាត្រា ៣</u>:** វិសោធនកម្ម

បណ្តាប្រព័ន្ធការពារធម្មជាតិនេះ អាចនឹងកែប្រែពង្រីកបន្ថែមនៅពេលអនាគត ដោយផ្អែកលើព័ត៌មាន វិទ្យាសាស្ត្រជាមូលដ្ឋានដែលទាក់ទងទៅនឹងអភិរក្សជីវសាស្ត្រ និង ការរក្សាឱ្យមានភាពស្ថិតស្ថេរ នៃទេសភាពនៅព្រះរាជាណាចក្រកម្ពុជា ។

## *គ) ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ*

ច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ ត្រូវបានអនុម័តដោយរដ្ឋសភាជាតិ កាលពីថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៦ ហើយបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស-រកម-១២៩៦-៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ។ ច្បាប់នេះមានគោលដៅ ÷

- ការពារលើកកំពស់គុណភាពបរិស្ថាន និង សុខភាពពលរដ្ឋ ដោយធ្វើការទប់ស្កាត់ ការកាត់បន្ថយ និង ការត្រួតពិនិត្យការបំពុល ។
- វាយតំលៃហេតុប៉ះពាល់បរិស្ថានមុននឹងចេញសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល ចំពោះរាល់គំរោងដែលបានស្នើឡើង ។
- ធានាឱ្យមានការអភិរក្ស ការអភិវឌ្ឍន៍ ការគ្រប់គ្រង និងការប្រើប្រាស់ដោយសមហេតុផល និងប្រកប ដោយនិរន្តរភាព និង ភាពស្ថិតស្ថេរនូវធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា ។
- លើកទឹកចិត្ត និងផ្តល់លទ្ធភាពឱ្យសាធារណជនចូលរួមក្នុងកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ ។
- បង្ក្រាបអំពើទាំងឡាយណាដែលធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន ។

នៅក្រោមច្បាប់នេះ អ្នកអភិវឌ្ឍន៍ទាំងឡាយចាំបាច់ត្រូវរៀបចំរបាយការណ៍ វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង (IEIA) ឬ របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ (EIA) សំរាប់គំរោងអភិវឌ្ឍន៍ដែលស្នើសុំ ឬ ដែលមានស្រាប់ដូចមានរៀបរាប់នៅក្នុងមាត្រាដូចតទៅ:

**<u>មាត្រា ៦</u>:**

ការវាយតំលៃហេតុប៉ះពាល់បរិស្ថានត្រូវអនុវត្តលើគំរោង និងសកម្មភាពរបស់ឯកជន ឬសាធារណៈហើយត្រូវបានពិនិត្យ និងវាយតំលៃដោយក្រសួងបរិស្ថាន មុនដាក់ជូនរាជរដ្ឋាភិបាលសំរេច ។

ការវាយតំលៃនេះក៏ត្រូវបានអនុវត្តផងដែរចំពោះសកម្មភាពដែលមានស្រាប់និងកំពុងដំណើរការ ហើយដែលពុំទាន់បានវាយតំលៃហេតុប៉ះពាល់បរិស្ថាននៅឡើយ ។

Draft

បែបបទនៃកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថានត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងបរិស្ថាន ។

ប្រភេទនិងទំហំគំរោង និងសកម្មភាពដែលស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់និងកំពុងដំណើរការទាំងឯកជននិងសាធារណៈ ដែលត្រូវមានការវាយតំលៃហេតុប៉ះពាល់បរិស្ថាននោះ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៧:**

ចំពោះរាល់ពាក្យសុំធ្វើគំរោងវិនិយោគ និងរាល់គំរោងដែលរដ្ឋស្នើឡើង ត្រូវមានការវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង (IEIA) ឬ ការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ (EIA) ដូចមានចែងក្នុងមាត្រា៦ នៃច្បាប់នេះ ។ ក្រសួងបរិស្ថានត្រូវពិនិត្យ និងផ្តល់យោបល់លើ IEIA ឬ EIA ទៅអង្គការមានសមត្ថកិច្ចក្នុងរយៈពេលដូចបានកំណត់ក្នុងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៨:**

ធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជាដែលមានជាអាទិ៍ ដី ទឹក អាកាស ខ្យល់ ភូគព្ភសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាត និង ឧស្ម័ន ថ្មនិងខ្សាច់ ត្បូងថ្មមានតំលៃ ព្រៃឈើនិងអនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆជាតិ ធនធានជលផល ត្រូវបានអភិរក្ស អភិវឌ្ឍន៍ និងគ្រប់គ្រង ហើយប្រើប្រាស់ដោយសមហេតុផល និងប្រកបដោយនិរន្តរភាព និងភាពស្ថិតស្ថេរ ។

តំបន់ការពារធនធានធម្មជាតិមានជាអាទិ ឧទ្យានជាតិ ជំរកសត្វព្រៃ តំបន់ការពារទេសភាពតំបន់ប្រើប្រាស់ច្រើនយ៉ាងត្រូវកំណត់ដោយព្រះរាជក្រឹត្យ ។

### ឃ) ច្បាប់ភូមិបាល

ច្បាប់ភូមិបាលនេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានអនុម័តនៅថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០០១ នាសម័យប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី ២ និងប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០០១។

**មាត្រា ៣:**

ជនគ្រប់រូបត្រូវគោរពទ្រព្យសម្បត្តិរបស់រដ្ឋ និងកម្មសិទ្ធិឯកជនស្របច្បាប់លើអចលនវត្ថុ។ ការគ្រប់គ្រងផ្នែករដ្ឋបាលសុរិយោដី លើអចលនវត្ថុដែលជាទ្រព្យសម្បតិរបស់រដ្ឋ និងការចេញប័ណ្ណកម្មសិទ្ធិលើអចលនវត្ថុទូទាំង ព្រះរាជាណាចក្រកម្ពុជា ជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ ។ បទបញ្ញា និងនិតិវិធីនៃការគ្រប់គ្រងអចលនវត្ថុដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ នឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៥:**



Draft

គ្មានបុគ្គលណាមួយត្រូវបានគេដកហូតកម្មសិទ្ធិរបស់ខ្លួនបានទេ ប្រសិនបើការដកហូតនេះមិនមែនដើម្បីប្រយោជន៍សាធារណៈ។ ការដកហូតត្រូវធ្វើទៅតាមទម្រង់និងនិតិវិធីបញ្ញត្តិដោយច្បាប់ និងបទបញ្ជាបន្ទាប់ពីបានផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌ ។

**មាត្រា ៧:**

របបកម្មសិទ្ធិលើអចលនវត្ថុមុនឆ្នាំ ១៩៧៩ មិនត្រូវបានទទួលស្គាល់ ។

**មាត្រា ២៣:**

សហគមន៍ជនជាតិភាគតិច គឺជាក្រុមមនុស្សដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានសមាជិកទាំងអស់បង្ហាញនូវការឯកភាពនៃជាតិពន្ធុ សង្គមវប្បធម៌សេដ្ឋកិច្ច ប្រតិបត្តិរបៀបរស់នៅតាមប្រពៃណី និងដាំដុះលើដីដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាតទំនៀមទំលាប់នៃការប្រើប្រាស់ជាសមូហភាព។ ក្នុងពេលរង់ចាំការកំណត់ ខាងផ្លូវច្បាប់នូវលក្ខន្តិកៈរបស់សហគមន៍ ក្រុមដែលមានជាក់ស្តែង មកទល់បច្ចុប្បន្ននេះនឹងបន្តគ្រប់គ្រងសហគមន៍ និង អចលនវត្ថុរបស់ខ្លួនតាមប្រពៃណី ហើយត្រូវអនុវត្តតាមបញ្ញត្តិនៃច្បាប់នេះ។

**មាត្រា ៣០:**

បុគ្គលទាំងឡាយដែលបានអាស្រ័យផលនៃភោគៈដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី ៥ (ប្រាំ) ឆ្នាំយ៉ាងតិចគិតមកដល់កាលបរិច្ឆេទនៃការប្រកាសឱ្យប្រើច្បាប់នេះលើអចលនវត្ថុ ដែលមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ក្នុងការកាន់កាប់ជាឯកជនមានសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិស្ថាពរ។ ក្នុងករណីមានការជំទាស់ដល់ការផ្តល់ប័ណ្ណ កម្មសិទ្ធិស្ថាពរ នេះ អ្នកតវ៉ាត្រូវយកភស្តុតាងមកបញ្ជាក់ថា ខ្លួនឯងផ្ទាល់បានបំពេញលក្ខខ័ណ្ឌនៃភោគៈដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី ៥ (ប្រាំ) ឆ្នាំ នៅលើអចលនវត្ថុដែលមានជំទាស់ ឬយកភស្តុតាងដែលថាខ្លួនបានទិញអចលនវត្ថុនោះពីភោគីដើម ឬពីសិទ្ធិវន្តស្របច្បាប់ ឬអ្នកទទួលផ្ទេរកម្មសិទ្ធិ ឬពីសន្តតិជនរបស់ខ្លួន ។

Draft

## ១) ច្បាប់ព្រៃឈើ

ច្បាប់ព្រៃឈើត្រូវបានអនុម័តដោយរដ្ឋសភាជាតិ នៅថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ ២០០២ និង ប្រកាសឱ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ នៅថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០០២។ មាត្រាពាក់ព័ន្ធសំខាន់ៗមានដូចតទៅ:

**មាត្រា១:**

ច្បាប់នេះកំណត់ក្របខណ្ឌនៃការគ្រប់គ្រង ការប្រមូលផល ការប្រើប្រាស់ ការអភិវឌ្ឍន៍ និង ការអភិរក្សព្រៃឈើនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ គោលបំណងនៃច្បាប់នេះ គឺធានានូវការគ្រប់គ្រងព្រៃឈើ ប្រកបដោយនិរន្តភាពដើម្បីផលប្រយោជន៍សង្គម សេដ្ឋកិច្ច និង បរិស្ថាន រួមទាំងការអភិរក្សជីវៈចំរុះ និង មរតកវប្បធម៌។

**មាត្រា២:**

ច្បាប់នេះមានវិសាលភាពអនុវត្តលើរាល់ព្រៃឈើទាំងអស់ ទោះជាប្រភេទព្រៃនោះកើតឡើងដោយធម្មជាតិក្តី ឬដោយដាំក្តី។ រដ្ឋធានាសិទ្ធិប្រើប្រាស់ជាប្រពៃណីនូវផល អនុផលព្រៃឈើរបស់សហគមន៍មូលដ្ឋាន ក្រោមបទបញ្ញត្តិនៃច្បាប់នេះ ឬច្បាប់ពាក់ពន្ធ័ផ្សេងទៀត។

**<u>មាត្រា ៣:</u>**

ការគ្រប់គ្រងព្រៃឈើត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចទូទៅនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។ ការគ្រប់គ្រងព្រៃលិចទឹកស្ថិតនៅក្រោមច្បាប់មួយដោយឡែក។

រដ្ឋផ្តល់សិទ្ធិគ្រប់គ្រងតំបន់ការពារធម្មជាតិដល់ក្រសួងបរិស្ថាន ក្រោមបទបញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធម្មជាតិ ចុះថ្ងៃទី ២៤ ធ្នូ ឆ្នាំ ១៩៩៦ ព្រះរាជក្រិត្យស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ និង លិខិតបទដ្ឋានច្បាប់ផ្សេងៗទៀត។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិសហការធ្វើសកម្មភាពពង្រឹងការអនុវត្តន៍ច្បាប់ ចំពោះរាល់បទល្មើសព្រៃឈើដែលកើតមាននៅក្នុងតំបន់ការពារធម្មជាតិ ក្រោមការសម្របសម្រួលជាមួយក្រសួងបរិស្ថានស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងជំពូកទី ១៤ នៃច្បាប់នេះ។ សកម្មភាពនេះនឹងមិនធ្វើអោយប៉ះពាល់ដល់ដែនសមត្ថកិច្ចគ្រប់គ្រងរបស់ ក្រសួងបរិស្ថាន ដូចមានចែងក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិឡើយ។

**<u>មាត្រា ៤:</u>**

ក្នុងការអនុវត្តន៍ច្បាប់នេះ រាល់ការសម្រេចរបស់រាជរដ្ឋាភិបាលដែលមានសក្តានុពលភាពចំពោះផលប៉ះពាល់ធ្ងន់ធ្ងរទៅលើប្រជាពលរដ្ឋទូទៅលើជីវភាពសហគមន៍មូលដ្ឋាននិងលើធនធានព្រៃឈើនៃព្រះរាជាណាចក្រកម្ពុជា ត្រូវមានការចូលរួមជាសាធារណៈ។

សកម្មភាពចំបងៗ ពាក់ពន្ធ័ទៅនឹងប្រពន្ធ័មជ្ឈដ្ឋានព្រៃឈើដែលអាចបណ្តាលឱ្យមានផលប៉ះពាល់អាក្រក់ដល់សង្គមនិងបរិស្ថានចាំបាច់ត្រូវមានការវាយតំលៃហេតុប៉ះពាល់បរិស្ថាននិងផលប៉ះពាល់សង្គម ដោយផ្អែកតាមក្រុមបច្ចេកទេសគ្រប់គ្រងព្រៃឈើកម្ពុជា និងស្របតាមច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ។ ឯកសារនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម ត្រូវផ្តល់ជូនសំរាប់ការចូលរួមផ្តល់មតិជាសាធារណៈបាន។

រាល់ការសំរេចចុងក្រោយលើរាល់សកម្មភាពចំបងៗ ពាក់ពន្ធ័ទៅនឹងប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើរាជរដ្ឋាភិបាលត្រូវពិចារណាលើអនុសាសន៍ចុងក្រោយនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម ។ ការសំរេចចុងក្រោយណាមួយក្រោមមាត្រានេះ រាជរដ្ឋាភិបាលអាចធ្វើការជូនដំណឹងជាសាធារណៈ ។

**<u>មាត្រា ៩៤:</u>**

បុគ្គលណាដែលបានប្រព្រឹត្តិបទល្មើសព្រៃឈើ ធ្វើឱ្យប៉ះពាល់ខូតខាតដល់មជ្ឈដ្ឋានព្រៃឈើត្រូវចេញ ថ្លៃស្តារ ឬជួសជុលការខូចខាត មានលក្ខខ័ណ្ឌដូចដើមឡើងវិញ។

Draft

## ច) ច្បាប់ជលផល

ច្បាប់ស្តីពីជលផល ត្រូវបានអនុម័តដោយរដ្ឋសភា នៅថ្ងៃទី ៣០ ខែមិនា ឆ្នាំ ២០០៦ និងប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ នៅថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០០៦។ មាត្រាពាក់ព័ន្ធសំខាន់ៗមានដូចតទៅ:

**<u>មាត្រាទី ៤:</u>**

ធនធានជលផលមានសរីរាង្គទឹកសាប និងសមុទ្រ ជាសត្វ និង រុក្ខជាតិ មានជីវិត ឬគ្មានជីវិត ជាអាទិ៍ មច្ឆជាតិ សិប្បីសត្វ ថលជលិក សត្វបាណកសត្វ ឧរង្គសត្វ ថនិកសត្វ សត្វឥតឆ្អឹងកងផ្សេងទៀតដែលបង្កកំណើតនៅក្នុងទឹក ឬដង់តុង សារាយ ស្មៅសមុទ្រ ផ្កាថ្ម ព្រៃលិចទឹកព្រម ទាំងព្រៃកោងកាងជាដើម ។

**<u>មាត្រាទី ១៨:</u>**

តំបន់គ្រប់គ្រងជលផលជា អាទិ៍ តំបន់ទឹកជ្រៅ អន្លង់ជ្រៅនៅតាមដងទន្លេ បឹងទន្លេសាប បឹង ព្រៃលិចទឹក តំបន់កោះ តំបន់ ស្មៅសមុទ្រ តំបន់ផ្កាថ្ម និងព្រៃកោងកាង ដែលជាកន្លែងមានសារៈសំខាន់ដល់និរន្តភាពនៃធនធានជលផលត្រូវរៀបចំចាត់ថ្នាក់ជាកន្លែងការពារ និង អភិរក្សធនធានជលផល ។

**<u>មាត្រាទី ២០:</u>**

ហាមឃាត់ដាច់ខាត ចំពោះការធ្វើនេសាទគ្រប់ប្រភេទនៅក្នុងដែននេសាទដោយប្រើឧបករណ៍ដូច ខាងក្រោមៈ

១- ឧបករណ៍ឆក់ គ្រឿងផ្ទុះ និងសារធាតុពុលគ្រប់ប្រភេទ ។

២- ឧបករណ៍បូម បាច ពង្រីងផ្ទៃកណាមួយនៃដែននេសាទដែលបង្កមហន្តរាយដល់ធនធានជលផល ។

៣- សម្រាស់ ឬមធ្យោបាយផ្សេងទៀតដែលធ្វើឱ្យត្រី ឬវារីសត្វកុំ ។

៤- ច្បូក សាង ស្ន ឧបករណ៍បាញ់ព្រួញដែលរួមផ្សំគ្រឿងផ្ទុះ ។

៥- មងបោះ មងកាំង ឬ មងពស់ថ្លាន់គ្រប់ប្រភេទ ។

៦- មង ឬ អួនគ្រប់ប្រភេទដែលមានក្រឡាតូចជាងមួយសង្ទីម៉ែត្រកន្លះ (១.៥ស.ម) ក្នុងដែននេសាទទឹកសាប

៧- មងគ្រប់ប្រភេទដែលមាក្រឡាធំជាងដប់ប្រាំ (១៥) សង្ទីម៉ែត្រក្នុងដែននេសាទទឹកសាប ។

៨- អួនអូសគូ ឬ អួនហ៊ុមរួមផ្សំភ្លើងដែលធ្វើឱ្យត្រី ឬវារីសត្វកុំ ។

៩- ឧបករណ៍នេសាទស្បៃមុងគ្រប់ប្រភេទនៅទឹកសាប ។

១០- អួនអូសគ្រប់ប្រភេទនៅទឹកសាប និងឈិបយន្ត ។

១១-ព្រួលគ្រប់ប្រភេទដែលមានចន្លោះពីត្រៀមមួយទៅត្រៀមមួយតូចជាងមួយសង្ទីម៉ែត្រកន្លះ (១.៥ស.ម)

១២-ខ្សែចងគ្រប់ប្រភេទ និងមធ្យោបាយផ្សេងៗទៀតដែលបង្កលក្ខណៈឱ្យត្រីផ្អើល ។

១៣-ទំនប់រួមផ្សំដោយឧបករណ៍នេសាទគ្រប់ប្រភេទ ។

១៤-ឧបករណ៍នេសាទទំនើប ឬ ឧបករណ៍នេសាទដែលបង្កើតថ្មី ឬ របៀបនេសាទបែបថ្មីដែលនាំមកនូវការបំផ្លាញមច្ឆជាតិ ធនធានជលផល ប្រព័ន្ធអេកូឡូស៊ីជលផល ឬ ដែលគ្មានកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រាទី ២២:**

ហាមឃាត់ ការចាក់ចោល ការបោះចោល ការបង្ហូរ ឬ ការបាចពង្រាយទៅក្នុងដែននេសាទនូវកាកសំណល់រឹង ឬរាវ ឬសារធាតុពុលដែលបានកំណត់កោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនៃព្រះរាជាណាចក្រ កម្ពុជានិងអនុសញ្ញា ឬសន្ធិសញ្ញាអន្តរជាតិស្តីពីការបំពុលបរិស្ថាន ឬការប្រព្រឹត្តិសកម្មភាពដែលធ្វើឱ្យពុល ឬ ការបង្កគ្រោះថ្នាក់ដល់វារីសត្វ និងវារីរុក្ខជាតិ។

**មាត្រាទី ២៥:**

ការធ្វើទំនប់កាត់ ឬ ការលុបទន្លេ ស្ទឹង ព្រែក អូរ បឹង ប្រឡាយ អាងទឹក និងអាងធម្មជាតិ ឬការជីក ប្រឡាយ អាងទឹក និងអាងធម្មជាតិ ឬការជីកប្រឡាយរណ្តៅ និងស្រះទ្រង់ទ្រាយ ឬ ការសាងសង់សំណង់ ថ្មីនានា ឬ ការបូមទឹកដែលអាចបង្កមហន្តរាយដល់ធនធានជលផលនៅក្នុងដែននេសាទ ត្រូវមានការសិក្សា វាយតំលៃពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងស្ថាប័នពាក់ព័ន្ធ។

Draft

## *ឆ) ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក*

ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកត្រូវបានអនុម័តដោយរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ ២០០៧។ មាត្រាពាក់ព័ន្ធសំខាន់ៗមួយចំនួនទាក់ទងនឹងគំរោងមាន:

**មាត្រា ៣:**

ទឹក និងធនធានទឹកជាសម្បត្តិរបស់រដ្ឋ ។

**មាត្រា ៥ :**

ក្រសួងធនធានទឹក និងឧតុនិយមមានភារកិច្ចគ្រប់គ្រង ដឹកនាំ និងត្រួតពិនិត្យ ក្នុងការអនុវត្តន៍ច្បាប់នេះ។ ក្រសួងធនធានទឹក និងឧតុនិយមត្រូវពិគ្រោះយោបល់ជាមួយនឹងក្រសួងពាក់ព័ន្ធនានា។ ក្នុងករណីចាំបាច់រាជរដ្ឋាភិបាលអាចនឹងបង្កើតគណៈកម្មការចំរុះចំពោះមុខដើម្បីដោះស្រាយ និងសម្របសម្រួលការងាររវាងបណ្តាក្រសួងពាក់ព័ន្ធ។

**មាត្រាទី ៧:**

ការសហការ និងចូលរួមរបស់ស្ថាប័នពាក់ព័ន្ធ ផ្នែកឯកជនអ្នកទទួលផលគ្រប់ប្រភេទ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិ នឹងត្រូវបានជំរុញដោយរាជរដ្ឋាភិបាលនៅក្នុងសកម្មភាពដែលទាក់ទងទៅនឹងការគ្រប់គ្រងការវិនិយោគ ការធ្វើអាជីវកម្ម ការអភិរក្ស និងការអភិវឌ្ឍន៍ធនធានទឹក។

**<u>មាត្រាទី ៨:</u>**

ក្រសួងធនធានទឹក និងឧតុនិយម មានភារកិច្ចរៀបចំ និងរក្សាទុកនូវរាល់សារពើភ័ណ្ឌធនធានទឹកនៃព្រះរាជាណាចក្រកម្ពុជា។ សារពើភ័ណ្ឌនេះ បង្ហាញអំពីទីតាំងបរិមាណ និងគុណភាពនៃធនធានទាំងនោះក្នុងរយៈពេលពេញមួយឆ្នាំទៅមួយឆ្នាំ ។

ទិន្នន័យស្តីពីបរិមាណ និងគុណភាពទឹក និងព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងទឹកដែលស្ថាប័ននានាប្រមូលបានត្រូវបញ្ជូនមកក្រសួងធនធានទឹក និងឧតុនិយមតាមស្តង់ដាបច្ចេកទេស ។

ព័ត៌មាន និងទិន្នន័យខាងលើនេះអាចផ្តល់ជូន បានដោយឥតគិតថ្លៃដល់គ្រប់ស្ថាប័នរាជរដ្ឋាភិបាល និងសហគមន៍នានា ក្នុងទិសដៅបំរើផលប្រយោជន៍សាធារណៈលើកលែងតែព័ត៌មាន និង ទិន្នន័យសម្ងាត់ ។

ក្រសួងធនធានទឹក និងឧតុនិយមអាចតម្រូវឱ្យមានការបង់ប្រាក់ចំពោះពាក្យសុំទាំងឡាយណាដែលធ្វើឡើងក្នុងគោលបំណងអាជីវកម្ម ។

**<u>មាត្រា ១១ :</u>**

បុគ្គលគ្រប់រូបមានសិទ្ធិប្រើប្រាស់ធនធានទឹកក្នុងបរិមាណមួយមិនលើសពីសេចក្តីត្រូវការចាំបាច់ជាមូលដ្ឋានសំរាប់ការហូបចុក បោកគក់ ងូត និងតំរូវការផ្សេងទៀត រួមមានការចិញ្ចឹមសត្វ ការចិញ្ចឹមត្រី ការស្រោចស្រពសួនច្បារ និង ដំណាំ ដោយជៀសវាងមិនអោយមានការប៉ះពាល់ដល់សិទ្ធិស្របច្បាប់របស់អ្នកដទៃ ។

**<u>មាត្រា ១២ :</u>**

ការបង្វែរទឹក ការយកទឹក ការប្រើប្រាស់ធនធានទឹក ក្នុងគោលបំណងកសិកម្ម ឬឧស្សាហកម្ម លើសពីកំរិតដែលមានចែងនៅក្នុងមាត្រា ១១ និងសំណង់ការងារទឹកដែលពាក់ព័ន្ធតំរូវអោយមានការសុំអាជ្ញាប័ណ្ណទឹក ឬលិខិតអនុញ្ញាតិ ។

Draft

**<u>មាត្រាទី ២២:</u>**

រាល់ការបញ្ចេញចោល ការទុកចោល ឬការរក្សាទុកនូវសារធាតុពុលដែលអាចធ្វើឱ្យប៉ះពាល់ដល់គុណភាពទឹក និងអាចបង្កគ្រោះថ្នាក់ដល់មនុស្ស សត្វ និងរុក្ខជាតិត្រូវតែសុំអាជ្ញាប័ណ្ណទឹក ឬការអនុញ្ញាតិ ។

ប្រភេទសារធាតុពុលដែលមានចែងខាងលើ និងស្តង់ដាបច្ចេកទេសនៃការបញ្ចេញទឹកសំណល់នឹងមានកំណត់ដោយអនុក្រឹត្យ ។

រាល់កិច្ចដំណើរការក្នុងមាត្រានេះ ក្រសួងធនធានទឹកនិងឧតុនិយមត្រូវពិគ្រោះយោបល់ជាមួយក្រសួងពាក់ព័ន្ធនានា ។

**មាត្រាទី ២៩:**

ក្នុងករណីដែលពិនិត្យឃើញថា សំណង់ការងារទឹកទាំងឡាយដែលមិនមានស្ថិរភាពគ្រប់គ្រាន់ ឬអាចនឹងបង្កឱ្យមានមហន្តរាយប៉ះពាល់ដល់សង្គមជាតិ ក្រសួងធនធានទឹកនិងឧតុនិយមត្រូវពិគ្រោះយោបល់ជាមួយក្រសួងពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានដើម្បីហាមឃាត់ជាបន្ទាន់ទៅតាមសមត្ថកិច្ចរៀងៗខ្លួន។

**មាត្រាទី ៣៤:**

ព្រះរាជាណាចក្រកម្ពុជាមានសិទ្ធិ និងកាតព្វកិច្ចចាត់ចែងចំណែកសមស្រប និងដោយស្មើភាពក្នុងការប្រើប្រាស់ ការអភិវឌ្ឍន៍ និងការគ្រប់គ្រងទន្លេអន្តរជាតិក្នុងទឹកដីរបស់ខ្លួនស្របតាមសិទ្ធិ និងកាតព្វកិច្ចដែលមានចែងក្នុងកិច្ចព្រមព្រៀងអន្តរជាតិ ដែលមានព្រះរាជាណាចក្រកម្ពុជាជាភាគី។

ក្រសួងធនធានទឹកនិងឧតុនិយមយកចិត្តទុកដាក់ឱ្យមានការប្រើប្រាស់ទឹកអាងទន្លេមេគង្គលើគ្រប់វិស័យ ដោយរួមទាំងវិស័យដឹកជញ្ជូនផងឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធិភាពស្របតាមគោលការណ៍របស់គណៈកម្មាធិការជាតិទន្លេមេគង្គ។

### ៤) អនុក្រឹត្យ ស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន

អនុក្រឹត្យលេខ ៧២ អនក្រ.បក ស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន បានចូលជាធរមាននៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៩ ។ មាត្រាពាក់ពន្ធ័សំខាន់ៗរួមមានដូចខាងក្រោម ÷

**មាត្រា ១:** អនុក្រឹត្យនេះមានគោលដៅ ÷

- កំណត់ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន លើរាល់គំរោង និងសកម្មភាពរបស់ឯកជន ឬ សាធារណៈហើយត្រូវបានពិនិត្យ និង វាយតំលៃដោយក្រសួងបរិស្ថានមុននឹងដាក់ជូនរាជរដ្ឋាភិបាលសំរេច។
- កំណត់ប្រភេទ និង ទំហំគំរោង សកម្មភាពដែលបានស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និង កំពុងដំណើរការទាំងឯកជន ទាំងសាធារណៈដែលត្រូវវាយតំលៃហេតុប៉ះពាល់បរិស្ថាន។
- បំផុសឱ្យមានការចូលរួមពីសាធារណជន ក្នុងកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ព្រមទាំងទទួលយកមតិយោបល់មកធ្វើការពិចារណាក្នុងកិច្ចដំណើរការអនុម័តគំរោង។

**មាត្រា ២:** អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះគំរោងដែលស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និង កំពុងដំណើរការដែលជាបុគ្គលឯកជន ជាក្រុមហ៊ុនចំរុះរដ្ឋ ឬជាក្រុមហ៊ុនរដ្ឋ ជាក្រសួង-ស្ថាប័នរដ្ឋ ដែលមានចែងនៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ លើកលែងតែគំរោងដែលមានលក្ខណៈពិសេស និង ចាំបាច់បន្ទាន់ដែលសំរេចដោយរាជរដ្ឋាភិបាល។

**មាត្រា ៣:** ក្រសួងបរិស្ថានមានភារៈកិច្ច :-



Draft

ក/- ពិនិត្យ និងវាយតំលៃលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ។

ខ/- តាមដានឃ្លាំមើល និងចាត់វិធានការអោយម្ចាស់គំរោងប្រតិបត្តិតាម ផែនការគ្រប់គ្រងបរិស្ថានក្នុងដំណាក់កាលសាងសង់ ប្រតិបត្តិ និងបញ្ចប់គំរោង ដូចមានចែងក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដែលបានអនុម័តរួច ។

<u>**មាត្រា៤**</u>: ស្ថាប័ន និងក្រសួង ដែលមានសិទ្ធិអនុម័តលើគំរោង មានភារៈកិច្ចពិនិត្យ និងសំរេចលើគំរោងដូចមានចែងក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ដែលក្រសួងបរិស្ថានបានពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ។

<u>**មាត្រា៧**</u>: ម្ចាស់គំរោងត្រូវដាក់ពាក្យសុំពិនិត្យរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង និងរបាយការណ៍ សិក្សាបុរេលទ្ធភាពទៅក្រសួងបរិស្ថាន ។

<u>**មាត្រា៨**</u>: ម្ចាស់គំរោងត្រូវដាក់ពាក្យសុំពិនិត្យរបាយការណ៍ វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ និងរបាយការណ៍សិក្សាសមិទ្ធិលទ្ធភាពទៅក្រសួងបរិស្ថាន ចំពោះគំរោងដែលអាចបង្កហេតុប៉ះពាល់បរិស្ថានធ្ងន់ធ្ងរដល់ធនធានធម្មជាតិ អេកូស៊ីស្តែមសុខភាព និងសុខមាលភាពសាធារណៈ ។

<u>**មាត្រា១៦**</u>: ក្នុងករណីដែលក្រសួងបរិស្ថានតម្រូវឱ្យមានរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ពេញលេញ ម្ចាស់គំរោងត្រូវរៀបចំ និងបញ្ជូនរបាយការណ៍ ដូចមានចែងក្នុងមាត្រា៨ទៅក្រសួងបរិស្ថាន ជាមួយនឹងការដាក់ពាក្យស៊ុំវិនិយោគទៅស្ថាប័នអនុម័តគំរោង ។

<u>**មាត្រា១៧**</u>: ក្រសួងបរិស្ថាន ត្រូវពិនិត្យរបាយការណ៍ ដូចមានចែងក្នុងមាត្រា ១៦ ព្រមទាំងចាត់បញ្ជូនយោបល់និង សំណើរទៅម្ចាស់គំរោង និងស្ថាប័នអនុម័តគំរោងក្នុងរយៈពេល ៣០ថ្ងៃ គិតថ្ងៃធ្វើការ ចាប់ពីថ្ងៃដែលក្រសួងបានទទួលរបាយការណ៍សិក្សាលទ្ធភាព និង របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ ពីម្ចាស់គំរោង ។

<u>**មាត្រា២០**</u>: មុនចាប់ដំណើរការអនុវត្តគំរោង ម្ចាស់គំរោងត្រូវទទួលយោបល់ឯកភាពពីក្រសួងបរិស្ថានលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូងឬរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

## *ឈ) អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលទឹក*

អនុក្រឹត្យលេខ ២៧ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលទឹក បានចូលជាធរមានចាប់ពីថ្ងៃទី ០៦ ខែមេសា ឆ្នាំ១៩៩៩ ។ មាត្រាសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងគំរោងមានដូចខាងក្រោម ÷

<u>**មាត្រា១**</u>: អនុក្រឹត្យនេះមានគោលដៅកំណត់ការត្រួតពិនិត្យការបំពុលទឹក ដើម្បីទប់ស្កាត់និងកាត់បន្ថយការបំពុលទឹក នៅតាមតំបន់ ទឹក សាធារណៈសំដៅធានាបានការការពារសុខភាពមនុស្ស និងការអភិរក្សជីវៈចំរុះ ។

**មាត្រា២:** អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះរាល់ប្រភពបំពុល និង រាល់សកម្មភាពទាំងឡាយដែលបង្កឱ្យមាន ការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ ។

**មាត្រា៨:** ហាមឃាត់ជាដាច់ខាតនូវការចាក់ចោលសំរាមសំណល់រឹង ឬសារធាតុប្រកបដោយគ្រោះថ្នាក់ទៅក្នុងតំបន់សាធារណៈ ឬប្រព័ន្ធលូសាធារណៈ ។ ហាមឃាត់ជាដាច់ខាតនូវការទុកដាក់ ឬការចាក់ចោលសំរាមសំណល់រឹង ឬសារធាតុ ប្រកបដោយគ្រោះថ្នាក់ ដែលនាំឱ្យមានការបំពុលទឹកទំបន់ទឹកសាធារណៈ ។

**មាត្រា២៥:** កំរិតកំណត់ស្តង់ដាគុណភាពទឹកនៅតាមតំបន់សាធារណៈសំរាប់អភិរក្សជីវៈចំរុះនៅក្នុងទឹក មានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ៤ នៃអនុក្រឹត្យនេះ ។

ឧបសម្ព័ន្ធ ៤: កំរិតកំណត់ស្តង់ដាគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈសំរាប់អភិរក្សជីវចំរុះនៅក្នុងទឹក

១- សំរាប់ទន្លេ

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | កំរិតស្តង់ដារ |
|---|---|---|---|
| 1 | pH | mg/l | 6.5 – 8.5 |
| 2 | $BOD_5$ | mg/l | 1 – 10 |
| 3 | សារធាតុរឹងអណ្តែតក្នុងទឹក (SS) | mg/l | 25 – 100 |
| 4 | កំរិតរលាយអុកស៊ីសែន (DO) | mg/l | 2.0 - 7.5 |
| 5 | កូលីហ្វម (Coliform) | MPN/100ml | < 5000 |

២- សំរាប់បឹង និង អាងស្តុកទឹក

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | កំរិតស្តង់ដារ |
|---|---|---|---|
| 1 | pH | mg/l | 6.5 – 8.5 |
| 2 | COD | mg/l | 1 – 8 |
| 3 | សារធាតុរឹងអណ្តែតក្នុងទឹក (SS) | mg/l | 1 – 15 |
| 4 | កំរិតរលាយអុកស៊ីសែន (DO) | mg/l | 2.0 - 7.5 |
| 5 | កូលីហ្វម (Coliform) | MPN/100ml | < 1000 |
| 6 | អាសូតសរុប (Total Nitrogen) | mg/l | 1.0 – 0.6 |
| 7 | ផូស្វរសរុប (Total Phosphorus) | mg/l | 0.005 – 0.05 |

៣- សំរាប់ទឹកសមុទ្រ

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | កំរិតស្តង់ដារ |
|---|---|---|---|
| 1 | pH | mg/l | 7.0 – 8.3 |
| 2 | COD | mg/l | 2 – 8 |
| 3 | កំរិតរលាយអុកស៊ីសែន (DO) | mg/l | 2 - 7.5 |

| | | | |
|---|---|---|---|
| 4 | កូលីហ្វម (Coliform) | MPN/100ml | < 1000 |
| 5 | សមាសធាតុប្រេង (Oil content) | mg/l | 0 |
| 6 | អាសូតសរុប (Total Nitrogen) | mg/l | 1– 1.0 |
| 7 | ផូស្វរសរុប (Total Phosphorus) | mg/l | 0.02 – 0.09 |

## ៣) *អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំណល់រឹង*

អនុក្រឹត្យលេខ ៣៦ អនក្រ.បក ស្តីពីការគ្រប់គ្រងសំណល់រឹង បានចូលជាធរមាននៅថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៩ ។

<u>**មាត្រា១**</u>: អនុក្រឹត្យនេះមានគោលដៅកំណត់ការគ្រប់គ្រងសំណល់រឹង ប្រកបដោយលក្ខណៈបច្ចេកទេសសមស្រប និងប្រកបដោយសុវត្ថិភាព សំដៅធានាបាននូវការការពារសុខភាពសាធារណៈ គុណភាពបរិស្ថាន និងការអភិរក្ស ជីវៈចំរុះ ។

<u>**មាត្រា២**</u>: អនុក្រឹត្យនេះមានវិសាលភាពអនុវត្ត ចំពោះរាល់សកម្មភាពបោះចោល ទុកដាក់ ស្តុក ប្រមូល ដឹកជញ្ជូន កែច្នៃ និងបញ្ចេញចោលសំរាម និងសំណល់ប្រកបដោយគ្រោះថ្នាក់ ។

<u>**មាត្រា៣**</u>: និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានបកស្រាយដូចតទៅ:

ក- "**សំណល់រឹង**" គឺសំដៅទៅលើវត្ថុរឹង សារធាតុរឹង ផលិតផល ឬរបស់កំទេចកំទី ដែលលែងត្រូវការប្រើប្រាស់ ហើយដែលត្រូវបានគេបោះបង់ចោល មានបំណងបោះបង់ចោល ឬតំរូវឱ្យបោះបង់ចោល ។

ខ- "**សំរាម**" គឺជាផ្នែកមួយនៃសំណល់រឹងដែលពុំមានផ្ទុកជាតិពុល ឬសារធាតុបង្កគ្រោះថ្នាក់ ហើយត្រូវបញ្ចេញពីលំនៅស្ថាន អាគារសាធារណៈ រោងចក្រ ទីផ្សារ សណ្ឋាគារ អាគារពាណិជ្ជកម្ម ភោជនីយដ្ឋាន មធ្យោបាយដឹកជញ្ជូន កន្លែងកំសាន្ត ។ល។

គ- "**សំណល់ប្រកបដោយគ្រោះថ្នាក់**" គឺសំដៅទៅលើសារធាតុវិទ្យុសកម្ម ផ្ទុះ ពុល ឆេះ បង្កឱ្យមានជំងឺមហារីក ចំលងជំងឺ ធ្វើឱ្យរលាក ធ្វើឱ្យច្រេះ ធ្វើអុកស៊ីតកម្ម ឬសារធាតុគីមីដទៃទៀត ដែលអាចនាំឱ្យមានគ្រោះថ្នាក់ដល់មនុស្ស សត្វ ឬមានការបំផ្លិចបំផ្លាញដល់រុក្ខជាតិ ទ្រព្យសម្បត្តិសាធារណៈនិងបរិស្ថាន។ សំណល់ប្រកបដោយគ្រោះថ្នាក់អាចមានប្រភពពីលំនៅដ្ឋាន រោងចក្រឧស្សាហកម្ម សកម្មភាពកសិកម្ម សកម្មភាពអាជីវកម្ម និង សេវាកម្ម អាជីវកម្មរ៉ែ ។ល។ ប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

<u>**មាត្រា៧**</u>: ហាមឃាត់ជាដាច់ខាត ការបោះចោលសំរាមនៅតាមទីសាធារណៈ ឬការចាក់ចោលសំរាមខុសទីកន្លែងដែលកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច ។

## ជ) អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និង ការរំខានដោយសំលេង

អនុក្រឹត្យលេខ ៤២អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់និងការរំខានដោយសំលេង បានចូលជាធរមានគតិយុត្តចាប់ពីថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០ ។

**មាត្រា១:** អនុក្រឹត្យនេះកំណត់ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេងដើម្បីទប់ស្កាត់ និងកាត់បន្ថយសារធាតុដែលបំពុលខ្យល់ និងសំលេងក្នុងបរិយាកាសសំដៅការពារគុណភាពបរិស្ថាន និងសុខភាពសាធារណៈ ។

**មាត្រា២:** អនុក្រឹត្យនេះមានវិសាលភាពអនុវត្ត និងចាត់វិធានការចំពោះរាល់ប្រភពបំពុលចល័ត និងអចល័តទាំងឡាយ ដែលបង្កឱ្យមានការបំពុលខ្យល់ និង ការរំខានដោយសំលេងនៅក្នុងបរិយាកាស ។

**មាត្រា៤:** កំរិតកំណត់ស្តង់ដាគុណភាពខ្យល់ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ១ នៃអនុក្រឹត្យនេះ

ឧបសម្ព័ន្ធ ១: កំរិតកំណត់ស្តង់ដាគុណភាពខ្យល់

| ល.រ | ប៉ារ៉ាម៉ែត្រ | រយៈពេល ១ ម៉ោង ជាមធ្យម $mg/m^3$ | រយៈពេល ៨ ម៉ោង ជាមធ្យម $mg/m^3$ | រយៈពេល ២៤ ម៉ោង ជាមធ្យម $mg/m^3$ | រយៈពេល ១ ឆ្នាំ ជាមធ្យម $mg/m^3$ |
|---|---|---|---|---|---|
| 1 | ការបូនអុកស៊ិត (CO) | 40 | 20 | - | - |
| 2 | អាសូតឌីអុកស៊ិត ($NO_2$) | 0.3 | - | 0.1 | - |
| 3 | ស្ពាន់ធ័រឌីអុកស៊ិត ($SO_2$) | 0.5 | - | 0.3 | 0.1 |
| 4 | អូសូន ($O_2$) | 0.2 | | | |
| 5 | សំណ (Pb) | | | 0.005 | |
| 6 | សារធាតុរឹងអណ្តែតក្នុងខ្យល់ (TSP) | - | - | 0.33 | 0.1 |

**កំណត់សំគាល់:** កំរិតកំណត់ស្តង់ដានេះអនុវត្តសំរាប់ធ្វើការវាយតំលៃគុណភាពខ្យល់ទូទៅ និង អង្កេតតាមដានស្ថានភាពនៃការបំពុលខ្យល់ ។ វិធីសាស្ត្រនៃការវិភាគគុណភាពខ្យល់នឹងត្រូវកំណត់តាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន ។

**មាត្រា១១:** ហាមឃាត់ដាច់ខាតការនាំចូល ប្រើប្រាស់ផលិតយានយន្ត និងគ្រឿងយន្តគ្រប់ប្រភេទក្នុងព្រះរាជាណាចក្រកម្ពុជា ដែលយានយន្ត និងគ្រឿងយន្តទាំងនោះបានបញ្ចេញសារធាតុបំពុល និងសំលេងមិនឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដាដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៤ និងឧបសម្ព័ន្ធ ៥ ។

ឧបសម្ព័ន្ធ ៥: កំរិតកំណត់ស្តង់ដាអតិបរមា ដែលអនុញ្ញាតបញ្ចេញសំលេងនៅលើផ្លូវសាធារណៈ ពីប្រភពយានយន្ត

| ល.រ | ប្រភេទយានយន្ត | កំរិតអតិបរិមា dB(A) |
|---|---|---|
| 1 | ទោចក្រយានចំណុះស៊ីឡាំង (CC) < $125cm^3$ | 85 |
| 2 | ទោចក្រយានចំណុះស៊ីឡាំង (CC) ≥ 125cm | 90 |
| 3 | ត្រីចក្រយានយន្ត | 90 |

| | | |
|---|---|---|
| 4 | រថយន្តធនតូច រថយន្តដឹកអ្នកដំណើរ < ១២ នាក់ | 80 |
| 5 | រថយន្តដឹកអ្នកដំណើរ ≥ ១២ នាក់ | 85 |
| 6 | រថយន្តដឹកអ្នកដឹកទំនិញដែលផ្ទុកទំនិញ < ៣.៥ តោន | 85 |
| 7 | រថយន្តដឹកទំនិញដែលផ្ទុកទំនិញ ≥ ៣.៥ តោន | 88 |
| 8 | រថយន្តដឹកទំនិញដែលផ្ទុកមានកម្លាំង ≥ ១៥០ kW | 89 |
| 9 | គ្រឿងយន្តផ្សេងទៀតដែលមិនបានរៀបរាប់ខាងលើ | 91 |

កំណត់សំគាល់: ករិតកំណត់ស្តង់ដារនេះអនុវត្តសំរាប់ការត្រួតពិនិត្យករិតបញ្ចេញសំលេងពីប្រភពយានយន្តគ្រប់ប្រភេទ ដែលកំពង់ធ្វើចរាចរលើផ្លូវសាធារណ:។

**មាត្រា១៨:** ការត្រួតពិនិត្យនូវការបញ្ចេញឧស្ម័ន និងសំលេងពីប្រភពចល័ត ជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ដោយមានកិច្ចសហការពីក្រសួងនិងស្ថាប័នពាក់ព័ន្ធ។ ចំពោះនីតិវិធីក្នុងការត្រួតពិនិត្យនេះ ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួង។

### ៥) អនុក្រឹត្យ ស្តីពីការបង្កើតតំបន់ព្រៃការពារអភិរក្សជីវចម្រុះជួរភ្នំក្រវាញភាគកណ្តាល និងជីវចំរុះ

អនុក្រឹត្យនេះត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា លេខ: ៧៧ អនក្រ.បក នៅថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០២ ។ មាត្រាសំខាន់មួយចំនួនជាប់ទាក់ទងនឹងគំរោងរួមមាន ÷

**មាត្រា១:** បង្កើតតំបន់ព្រៃការពារអភិរក្សជីជំរាលជួរភ្នំក្រវាញភាគកណ្តាល និងជីវចំរុះស្ថិតក្នុងខេត្តកោះកុង ពោធិសាត់ និងកំពង់ស្ពឺ ក្នុងគោលបំណង:-

- ការពារ និងអភិរក្សរុក្ខជាតិ និងសត្វព្រៃគ្រប់ប្រភេទ ជាពិសេសប្រភេទដែលកំពុងទទួលរងគ្រោះ និងប្រភេទជិតផុតពូជ
- រក្សាលំនឹងមជ្ឈដ្ឋានធម្មជាតិ ដែលជាទីជំរកសំរាប់ការស្នាក់អាស្រ័យ និង ការបន្តពូជរបស់ប្រភេទសត្វព្រៃ
- សិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកទេស ដើម្បីអភិវឌ្ឍ និងអភិរក្សជីជំរាល និង ជីវចំរុះ
- ការពារការហូរច្រោះ ទឹកជំនន់រក្សានូវសុក្រឹត្យភាពនៃប្រភពទឹក និងគុណភាពទឹក ទប់ទល់ការបាត់បង់ជីជាតិរបស់ដី
- ជំរុញការអប់រំ ផ្សព្វផ្សាយ និងអភិវឌ្ឍសហគមន៍
- ថែរក្សា និង អភិវឌ្ឍវិស័យទេសចរធម្មជាតិ
- ថែរក្សានូវកេរ្តិ៍តំណែលវប្បធម៌ប្រវត្តិសាស្ត្រ ដែលមាននៅក្នុងតំបន់

**មាត្រា២:** តំបន់ព្រៃការពារអភិរក្សជីជំរាលជួរភ្នំក្រវាញភាគកណ្តាល និង ជីវ:ចំរុះមានផ្ទៃក្រឡា ៤០១.៣១ ហិកតា។ សូមមើលរូបភាពបានភ្ជាប់ខាងក្រោម:

Draft

**មាត្រា៣:** ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ត្រូវធ្វើការរៀបចំនិងគ្រប់គ្រងតំបន់ព្រៃការពារអភិរក្សដីជំរាលជួរភ្នំក្រវាញភាគកណ្តាលនិងជីវៈចំរុះ ដោយសហការជាមួយក្រសួងពាក់ព័ន្ធដើម្បីធានានូវការអភិវឌ្ឍធនធានធម្មជាតិប្រកបដោយនិរន្តភាព សំរាប់ជីវភាពរស់នៅរបស់ប្រជាជនក្នុងតំបន់នោះ ។

## ខ) អនុក្រឹត្យ ស្តីពីការបង្កើតតំបន់ព្រៃការពារសំរាប់អភិរក្សជីវចំរុះ ការពារច្រករបៀងសត្វដំរី និងមជ្ឈ មណ្ឌលស្តារលទ្ធភាពដែលទ្រទ្រង់លក្ខណៈជីវសាស្ត្រសត្វព្រៃ និងអេកូ-ទេសចរណ៍

អនុក្រឹត្យនេះត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា លេខៈ ៦៥ អនក្រ.បក នៅថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ ២០០៤ ។ មាត្រាសំខាន់មួយចំនួនជាប់ទាក់ទងនឹងគំរោងរួមមាន ÷

**មាត្រា៤:** តំបន់ព្រៃការពារ សម្រាប់អភិរក្សជីវចំរុះ ការពារច្រករបៀងសត្វដំរី និងមជ្ឈមណ្ឌលស្តារលទ្ធភាពដែលទ្រទ្រង់លក្ខណៈជីវសាស្ត្រសត្វព្រៃខេត្តកោះកុង មានផ្ទៃក្រឡា ១៤៤២៧៥ ហិកតា ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធជាប្រព័ន្ធ ខ្សែព្រំបិទ កំណត់ដោយបណ្តាចំណុចគោលដែលមាននិយាមការ: • –

A(334074, 1237322); B(333958, 1251538); C(340637,1253405); D(338380, 1273232); E(326516, 1273260); F(320548, 1278873); G(314321, 1290020); H(309322, 1286590); I(291133, 1296529); J(280058, 1284999); K(283977, 1284463); L(287514, 1283233); M(289023, 1280539); N(297890, 1269927); O(306462, 1258808).

ការកែប្រែផ្ទៃក្រឡាតំបន់ព្រៃការពារសម្រាប់អភិរក្សជីវចំរុះការពារច្រករបៀងសត្វដំរី និងមជ្ឈមណ្ឌលស្តារលទ្ធភាពដែលទ្រទ្រង់លក្ខណៈជីវសាស្ត្រសត្វព្រៃខេត្តកោះកុងនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា៥:** សកម្មភាពគំរាមកំហែងដល់តំបន់ព្រៃការពារសំរាប់អភិរក្សជីវចំរុះ ការពារច្រករបៀងសត្វដំរី និងមជ្ឈមណ្ឌលស្តារលទ្ធភាពដែលទ្រទ្រង់លក្ខណៈជីវសាស្ត្រសត្វព្រៃខេត្តកោះកុង ដូចខាងក្រោមត្រូវហាមឃាត់ដាច់ខាត:

- ការកែច្នៃផល អនុផលព្រៃឈើ ឬការបង្កើត និងដំណើរការមូលដ្ឋានឧស្សាហកម្ម សិប្បកម្មផ្សេងៗ និងឡគ្រប់ប្រភេទ
- ការគាស់កកាយរករ៉ែ យកផ្ទាំងសិលាដុតយកកំបោរ ឬថ្មរួង ឬគាស់កកាយដីច្រាប
- ការប្រមូលផល អនុផលព្រៃឈើ និងសកម្មភាពបរបាញ់ ដែលបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរដល់ព្រៃឈើ និងសត្វព្រៃគ្រប់ប្រភេទ
- ការកាប់រានដីព្រៃធ្វើកម្មសិទ្ធិ និង ការតាំងលំនៅដ្ឋានថ្មី ។

## គ) គោលនយោបាយធនធានទឹកជាតិ

គោលនយោបាយនេះត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីនៅសម័យប្រជុំពេញអង្គ ថ្ងៃទី ១៦ មករា ២០០៤។ គោលបំណងរបស់គោលនយោបាយធនធានទឹកជាតិគឺ÷

- ដើម្បីការពារ គ្រប់គ្រង និងប្រើប្រាស់ធនធានទឹកប្រកបដោយប្រសិទ្ធភាព សមភាព និងមានលក្ខណៈសមស្រប .



Draft

- ដើម្បីទស្សន៍ទាយ និងធ្វើការវាស់វែងដើម្បីជួយដល់ស្ថាប័នដែលទាក់ទងដោះស្រាយបញ្ហាប្រឈមមុខ ដែលអាចកើតឡើងនៅក្នុងផ្នែកទឹក។

- ដើម្បីអភិវឌ្ឍន៍ និងអនុវត្តយុទ្ធសាស្ត្រជាតិ និង បង្កើតគោលនយោបាយជាតិ និង គោលនយោបាយលើវិស័យគ្រប់គ្រងធនធានទឹក។

- ដើម្បីតំរង់ទិសដល់ការអភិវឌ្ឍន៍ធនធានទឹក ការគ្រប់គ្រង និង ការប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ចំពោះគ្រប់សកម្មភាពរបស់ស្ថាប័ន ផ្នែកឯកជន និង ផ្នែកសាធារណៈ និង

- ដើម្បីកែលំអ និង លើកកំពស់ការរស់នៅរបស់ប្រជាជនដើម្បីសំរេចបានតាមគោលនយោបាយជាតិលើការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិអោយមាននិរន្តភាព។ នៅក្នុងផ្នែកទី ៤.២.២ "ទឹកសំរាប់ថាមពល" ប្រទេសកម្ពុជាមានសក្តានុពលសំរាប់ការអភិវឌ្ឍន៍ថាមពលវារីអគ្គិសនី ប្រហែល ១០០០០ មេហ្គាវ៉ាត់ ដែល ៥០% ស្ថិតនៅក្នុងទន្លេសំខាន់ៗ ៤០% ស្ថិតនៅក្នុងដៃទន្លេ និង ១០% ស្ថិតនៅក្នុងតំបន់ឆ្នេរ ប៉ុន្តែមានត្រឹមតែ ១៣ មេហ្គាវ៉ាត់ប៉ុណ្ណោះដែលបានអភិវឌ្ឍន៍រួចៈ រោងចក្រវារីអគ្គិសនីអូរជុំ (១មេហ្គាវ៉ាត់) និងរោងចក្រវារីអគ្គិសនីគីរីរម្យ I (១២មេហ្គាវ៉ាត់)។ រោងចក្រវារីអគ្គនិសនីកំចាយកំពង់ស្ថិតនៅក្នុងការសាងសង់ (១៩២ មេហ្គាវ៉ាត់)។ ការអភិវឌ្ឍន៍វារីអគ្គិសនីមានគុណប្រយោជន៍ក្នុងការផ្តល់ការកាត់បន្ថយភាពក្រីក្រ និងជំរុញសេដ្ឋកិច្ចកម្ពុជា។ វាមិនត្រឹមតែផ្តល់នូវថាមពលអគ្គិសនីដល់តំបន់ទីក្រុង និងជនបទប៉ុណ្ណោះទេ ប៉ុន្តែអាចបង្កលក្ខណៈងាយស្រួលដល់កសិកម្ម ការពារទឹកជំនន់ និងកសិ-ឧស្សាហកម្មនៅក្នុងតំបន់ជនបទផងដែរ ដែលជាទីផ្សារយ៉ាងសំខាន់សំរាប់កសិករ។ ដើម្បីបញ្ចាក់ពីបញ្ហាខាងលើ និងដើម្បីទទួលបានគុណប្រយោជន៍ពេញលេញពីធនធានទឹក រាជរដ្ឋាភិបាលកម្ពុជាមានគោល នយោបាយដូចតទៅៈ

១- ដើម្បីជំរុញ និង លើកទឹកចិត្តការសិក្សាស្រាវជ្រាវសំរាប់ការអភិវឌ្ឍន៍វារីអគ្គិសនីខ្នាតតូច មធ្យម និង ខ្នាតធំលើសក្តានុពលនៃការប្រើប្រាស់ទឹកសំរាប់វារីអគ្គិសនីដោយរាប់បញ្ចូលទាំងតំលៃ និង ផលកំរៃ។

២- ដើម្បីជំរុញការវិនិយោគ និងការធ្វើអាជីវកម្មនៅគ្រប់កំរិតនៃការអភិវឌ្ឍន៍វារីអគ្គិសនី ដោយរាប់បញ្ចូលឱ្យគ្រប់តាមតំរូវការរបស់អ្នកក្រ សហគមន៍តូចៗ និង/ឬ សហគមន៍ដាច់ស្រយាលសំរាប់ការលៃលកប្រើប្រាស់អគ្គិសនី។

### ណ) ស្តង់ដាបច្ចេកទេសថាមពលអគ្គិសនីរបស់ព្រះរាជាណាចក្រកម្ពុជា

ស្តង់ដាត្រូវបានបោះពុម្ពដោយអាជ្ញាធរអគ្គិសនីកម្ពុជា ខែ សីហា ឆាំ ២០០៧។ នៅក្នុងផ្នែកទី ៣ៈ លក្ខខណ្ឌទូទៅចំពោះមធ្យោបាយផលិតកម្មវារីអគ្គិសនី។

**ជំពូកទី ២ៈ លក្ខខណ្ឌទូទៅសំរាប់មធ្យោបាយអគ្គិសនី**

**ផ្នែកទី៣ៈ លក្ខខណ្ឌទូទៅចំពោះមធ្យោបាយផលិតកម្មវារីអគ្គិសនី**

**<u>មាត្រា ២៦ៈ</u> ទំនប់ ផ្លូវទឹក រោងម៉ាស៊ីនអគ្គិសនី និងគ្រឿងបន្ទាប់បន្សំផ្សេងទៀត**



Draft

### ២៦.១ ការបង្ការការហៀរទឹកចេញតាមផ្នែកដែលមិនត្រូវហៀរ នៃទំនប់

ទំនប់នីមួយៗត្រូវបំពាក់ពីលើ ឬក្បែរតួរបស់វានូវផ្លូវបង្ហៀរមួយដែលអាចបង្ហូរចេញដោយសុវត្ថិភាព និងគ្មានគ្រោះថ្នាក់ នូវបរិមាណទឹកដែលមានលើសពីការគ្រោងទុក ហើយតួទំនប់នីមួយៗត្រូវមានរបាំងគ្រប់គ្រាន់មួយសំរាប់បង្ការការហៀរទឹកចេញតាមផ្នែក ដែលមិនត្រូវហៀរនៃទំនប់ដើម្បីសុវត្ថិភាពរបស់ទំនប់ ។

### ២៦.២ លំនឹងរបស់ទំនប់

១. តួទំនប់ និងតួទំនប់ដែលបំពេញថែមត្រូវតែមានលំនឹង ចំពោះការរអិល ក្រឡាប់ ព្រមទាំងមានភាពមាំ និងជាប់បានយូរ ។

២. គ្រឹះនៃទំនប់ និងកន្លែងតភ្ជាប់រវាងតួទំនប់ និងគ្រឹះរបស់វាត្រូវតែមានលំនឹងចំពោះការរអិលចេញ ហើយត្រូវមានភាពមាំតាមការតម្រូវ ។

### ២៦.៣ ការបង្ការការខូចខាតទំនប់ដោយការជ្រាបទឹក

១. គ្រឹះទំនប់ ត្រូវធ្វើឱ្យបានហាប់ណែនល្អមិនជ្រាបទឹក ហើយមិនត្រូវមានការជ្រាបទឹកនៅគ្រឹះទំនប់ឡើយ

២. តួទំនប់ត្រូវមានភាពហាប់ណែនល្អមិនជ្រាបទឹក ។ មិនត្រូវពូនដីលើសនៅក្រោមតួទំនប់បេតុងទេ ។ មិនត្រូវបណ្តោយឱ្យមានការជ្រាបទឹកនៅតួទំនប់ ដែលបំពេញបន្ថែមឡើយ ។

៣. មិនត្រូវបណ្តោយឱ្យមានការជ្រាបទឹកកើតឡើងនៅកន្លែងតភ្ជាប់គ្នារវាងរតួទំនប់ និងគ្រឹះរបស់វាឡើយ ។

### ២៦.៤ ការបង្ការការខូចទ្រង់ទ្រាយធ្ងន់ធ្ងរនិងការប្រេះនៃទំនប់

១. គ្រឹះទំនប់ត្រូវតែមានសមត្ថភាពទ្រទំនប់ឱ្យបានគ្រប់គ្រាន់តាមតម្រូវការ

២. មិនត្រូវមានការប្រេះធ្ងន់ធ្ងរកើតឡើង នៅតួទំនប់បេតុងទេ

៣. តួទំនប់ដែលបំពេញបន្ថែមត្រូវតែពាស់ទប់ដោយវត្ថុធាតុសមស្រប ដើម្បីការពារការស្រុតចុះ និងការប្រេះធ្ងន់ធ្ងរ

### ២៦.៥ ការបង្ការការខូចផ្លូវទឹក

១. ផ្លូវទឹកត្រូវមានលំនឹងផ្នែករចនាសម្ព័ន្ធសំរាប់បន្ទុក ដែលបានគ្រោងទុក ហើយមិនត្រូវមានការខូចខាតដោយគ្រោះមហន្តរាយដូចជាការរអិលផ្ទាំងដី និងទឹកជំនន់ឡើយ ។

២. ផ្លូវទឹកត្រូវតែមានសមត្ថភាព អាចបង្ហូរទឹកដោយសុវត្ថិភាព និងគ្មានគ្រោះថ្នាក់ ហើយអាចគ្រប់គ្រងបរិមាណទឹកបង្ហូរចេញ ដែលបានគ្រោងរបស់រោងចក្រ និងត្រូវមានលំនឹងធារាសាស្ត្រ ។

### ២៦.៦ ការបង្ការការខូចរោងម៉ាស៊ីនអគ្គិសនី និងមធ្យោបាយដទៃទៀត

រចនាសម្ព័ន្ធ ដែលទាក់ទងទៅនឹងមធ្យោបាយវិស្វកម្ម សំណង់ស៊ីវិលនៃវារីអគ្គិសនី ដូចជារោងម៉ាស៊ីនអគ្គិសនី ផ្លូវសំរាប់ធ្វើការជួសជុល និងមធ្យោបាយបណ្តោះអាសន្នសំរាប់ការងារសំណង់ ត្រូវតែមានលំនឹងសំរាប់បន្ទុកដែលបានគ្រោងទុក ហើយមិនត្រូវរងនូវការខូចដោយរអិលផ្ទាំងដី និង ទឹកជំនន់ឡើយ ។

Draft

**<u>មាត្រា ២៧:</u> ការបង្កាការខូចរោងចក្រវារីអគ្គិសនី**

***២៧.១ ការបង្ការការខូចអាងស្តុកទឹកនិងដីនៅជុំញវិញអាងស្តុកទឹក***

២. ចំពោះអាងស្តុកទឹកមិនត្រូវបណ្តោយឱ្យមានការជ្រាបទឹកដែលមានគ្រោះថ្នាក់ដល់ដីជុំវិញ ការជ្រាបទឹកមិនប្រក្រតីក្នុងដី និងការរអិលផ្ទាំងដីក្នុងទំហំធំធេងនោះទេ ។

៣. ត្រូវមានវិធានការត្រឹមត្រូវ ប្រសិនបើមានការលិចលង់ដល់ទ្រព្យសម្បត្តិ ដូចជាផ្ទះសំបែង និងអគារនៅតំបន់ខាងលើនៃអាងស្តុកទឹក ដែលបណ្តាលមកពីការឡើងកំរិតទឹក បង្កដោយកំណើនកករដីនៃអាងស្តុកទឹក ។

***២៧.២ ការបង្ការការខូចតំបន់ក្រោមទំនប់ និងតំបន់ច្រកចេញ***

១. ការខូចបណ្តាលមកពីការបង្ហូរទឹកចេញពីទំនប់ទៅតំបន់ខាងក្រោម ក្នុងលក្ខខណ្ឌទឹកជំនន់មិនត្រូវកើនលើសពី ការខូចក្នុងករណីដែលគ្មានទំនប់នោះទេ ។

២. ត្រូវមានវិធានការត្រឹមត្រូវ ប្រសិនបើអាចកើតមានការខូចខាតដល់មនុស្ស ឬទ្រព្យសម្បត្តិ និងប៉ះពាល់ដល់បរិស្ថានជុំវិញ និងអ្វីផ្សេងៗទៀតនៅតំបន់ខាងក្រោម ដែលបណ្តាលមកពីការបង្ហូរទឹកចេញពីទំនប់ ។

៣. ត្រូវមានវិធានការត្រឹមត្រូវ ប្រសិនបើការផ្លាស់ប្តូរកំរិតកំពស់ទឹកដ៏ឆាប់រហ័ស នៅតំបន់ខាងក្រោមនៃច្រកបញ្ចេញទឹកដោយសារការបង្ហូរទឹកចេញពីរោងចក្រវារីអគ្គិសនី អាចបណ្តាលឱ្យមានការខូចខាតដល់តំបន់ខាងក្រោម ។

## ២.៣ ដំណើរការការវាយតំលៃហេតុប៉ះពាល់បរិស្ថាននៅក្នុងប្រទេសកម្ពុជា

ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងអនុក្រឹត្យស្តីពីដំណើរការការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ប្រើជាឧបករណ៍ផែនការបរិស្ថានសំរាប់ការអភិវឌ្ឍន៍គំរោងនៅប្រទេសកម្ពុជា ដោយតំរូវឱ្យមាន "ការវាយតំលៃ ហេតុប៉ះពាល់បរិស្ថាន គួរត្រូវបានធ្វើឡើងរាល់គំរោងនិងសកម្មភាពឯកជន និងសាធារណៈ និង ត្រូវបានពិនិត្យនិងវាយ តំលៃដោយក្រសួងបរិស្ថាន មុនពេលដាក់ជូនទៅរាជរដ្ឋាភិបាលសំរាប់ការធ្វើសេចក្តីសំរេច" (មាត្រា ៦ នៃច្បាប់) ។ អនុក្រឹត្យស្តីពី កិច្ចដំណើរការការវាយតំលៃហេតុប៉ះពាល់បរិស្ថាន បានបញ្ជាក់ថារបាយការណ៍ IEIA/EIA ត្រូវដាក់ជូនជាមួយ ឯកសារសិក្សាសមិទ្ធិលទ្ធភាពរបស់គំរោង ទៅក្រសួងបរិស្ថានសំរាប់ធ្វើការត្រួតពិនិត្យ និង ការអនុម័តយល់ព្រម ។ ចំពោះការប្រព្រឹត្តទៅនៃគំរោងបច្ចុប្បន្ននេះ ម្ចាស់គំរោង "CTHL" ចាំបាច់ត្រូវដាក់ជូនរបាយការណ៍ EIA ជាមួយរបាយការណ៍សិក្សាសមិទ្ធិលទ្ធភាពគំរោងវារី អគ្គិសនីស្ទឹងតាតៃ ទៅក្រសួងបរិស្ថាន ។

រូបភាពខាងក្រោមនេះ គឺបានបង្ហាញពីដំណើរការ EIA សំរាប់គំរោងបានស្នើឡើងដែលអនុម័តយល់ព្រមដោយគំនូសបំព្រួញខាងក្រោមបង្ហាញពីដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថានសំរាប់គំរោងស្នើសុំ ដែលអនុម័តដោយ រាជរដ្ឋាភិបាល (RGC) ឬ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ។

Draft

## កិច្ចដំណើរការ វ.ហ.ប សំរាប់គំរោងស្នើសុំ ដែលអនុម័តដោយរាជរដ្ឋាភិបាល ឬ ក.អ.ក




**គំណត់សំគាល់:**

ម.គ : ម្ចាស់គំរោង
ក.ប : ក្រសួងបរិស្ថាន
ក.អ.ក: ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
ព.វ : ពាក្យសុំវិនិយោគ
ព.ប.ប: ពាក្យសុំពិនិត្យបញ្ហាបរិស្ថាន
វ.ហ.ប.ដ: ការវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង
វ.ហ.ប: ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន
ផ.គ.ប: ផែនការគ្រប់គ្រងបរិស្ថាន